# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ទៅជា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការបង្កើត វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៣៩២ ស្ជន អយក.ឧស ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១** : ទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានគ្រប់គ្រង និងសេដ្ឋកិច្ច ទៅជា **សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច** " **University of Management and Economics** " ហៅកាត់ជាភាសាខ្មែរ " ស.គ.ស " និងហៅកាត់ជាភាសាអង់គ្លេស " **UME** "។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ៧៤ ក្រុមទី៤ ភូមិព្រែកព្រះស្តេច ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបច្ចុប្បន្នមានសាខាចំនួន ៥កន្លែង នៅតាមបណ្តាខេត្ត-ក្រុងផ្សេងទៀត ដូចជា : នៅខេត្តកំពង់ចាម ខេត្តកំពត ខេត្តពោធិសាត់ ខេត្តបន្ទាយមានជ័យ និងក្រុងព្រះសីហនុ។

**មាត្រា ២** : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងសាខាទាំងអស់របស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣** : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេស ឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- រៀបចំកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រ ជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រតាមឯកទេសរបស់សាកលវិទ្យាល័យ។
- កសាងផែនការអភិវឌ្ឍសម្រាប់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- គ្រប់គ្រង និយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

**មាត្រា ៤** : សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំឱ្យមាន មហាវិទ្យាល័យ ចំនួន ៥ គឺ :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យនីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច អាចបើក មហាវិទ្យាល័យ ឬសាខា ឬឯកទេស ឬប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥ :** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល របស់ ស.គ.ស និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវគ្រប់គ្រងដោយ សាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨ :** សាកលវិទ្យាធិការមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ហើយមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្ត តាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ. ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី .
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ